


Notice
Can't identify browser version. Agent: Mozilla/5.0 (Macintosh; Intel Mac OS X) AppleWebKit/534.34 (KHTML, like Gecko) Qt/4.8.7 Safari/534.34

## បច្ចុប្បន្នភាពនៃជំងឺកូរូណាថ្មី COVID-19 នៅប្រទេសកម្ពុជា




**COVID-19 Updated 21-03-2020**

ម៉ោង ២០ៈ00 ថ្ងៃទី ២១ ខែមីនា ឆ្នាំ ២០២០

- រកឃើញ ២ករណីថ្មីទៀត ជាបុរសទេសចរជនជាតិបារាំង វិជ្ជមានវីរុសកូវីត១៩ ធ្វើឱ្យចំនួនអ្នកឆ្លងសរុបនៅក្នុងប្រទេសកម្ពុជា កើនដល់៥៣នាក់។
- ចំណែកស្រ្តីជនជាតិអង់គ្លេស (ពិការ) វ័យ ៦៥ឆ្នាំ អវិជ្ជមានវីរុសកូវីត១៩ ចំនួន២លើក



Read more: បច្ចុប្បន្នភាពនៃជំងឺកូរូណាថ្មី COVID-19 នៅប្រទេសកម្ពុជា

## មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយៈដំណក់ទឹកតូចៗ ដែលខ្ទាតចេញមកក្រៅ តាមរយៈការក្អកឬកណ្តាស់

***Updated: 19/March/2020***

   

មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយៈដំណក់ទឹកតូចៗ ដែលខ្ទាតចេញមកក្រៅតាមរយៈក្អកឬកណ្តាស (មិនមែនហោះហើរក្នុងខ្យល់ទេ) ។ ត្រូវចងចាំថា ដំណក់ទឹកតូចៗអ្នកជំងឺដល់ទីណា មេរោគនឹងទៅដល់ទីនោះ ។អ្នកវិទ្យាសាស្រ្តរកឃើញថា ចំងាយខ្ទាតចេញពីមុខមនុស្សយើងចំងាយបាន ៣ហ្វីត បើគិតពីរង្វាស់ម៉ែត្រគឺ ៩0សង់ទីម៉ែត្រ ។ ដូច្នេះបើយើងនៅឆ្ងាយពីអ្នកជំងឺលើសពី១ម៉ែត្រ យើងនឹងគេចផុតពីដំណក់ទឹកតូចៗទាំងនោះ ។
ពេលអ្នកជំងឺក្អកឬកណ្តាសម្តងៗ បណ្តាលឱ្យខ្ទាតទៅលើផ្ទៃផ្សេងៗ ដូចជាលើតុ លើជញ្ជាំង លើបង្កាន់ដៃ ។ ល។ និងដៃរបស់គាត់ក្រោយញីច្រមុះប្រលាក់សំបោរ ប៉ះដៃទ្វារប៉ះជញ្ជាំងប៉ះបង្កាន់ដៃ ដែលអ្នកជាប៉ះផ្ទៃទាំងនោះបណ្តាលឱ្យឆ្លងពេលយើងប៉ះមុខនិងច្រមុះ ។អ្នកវិទ្យាសាស្រ្តរកឃើញថា ក្នុងមួយថ្ងៃមនុស្សយើងប៉ះមុខជាមធ្យម ៦0ដង ។ ហេតុដូច្នេះ តំរូវឱ្យអ្នកជំងឺត្រូវពាក់ម៉ាស់ដើម្បីកុំឱ្យខ្ទាតចេញមកក្រៅ នឹងទាំងអ្នកឈឺនិងអ្នកជាត្រូវតែឧស្សាហ៍លាងដៃជាមួយសាប៊ូ អាល់កុល ដេល ជាដើម ។ ចំពោះអ្នកជាពុំចាំបាច់ពាក់ម៉ាស់ទេ គឺយើងពាក់ម៉ាស់នៅពេលចាំបាច់ដូចជា កន្លែងប្រមូលផ្តុំ សួរសុខទុកអ្នកជំងឺ និងក្រុមគ្រូពេទ្យ ហើយគ្រវាត់ម៉ាស់ក្នុងធុងសំរាមភ្លាមក្រោយប្រើប្រាស់ ។
ពត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

## លេខ ១១៥ មានអ្នកទូរស័ព្ទចូលរហូតដល់ ជាង៩៣ម៉ឺននាក់ គិតចាប់ពីពេលរកឃើញកូវិត១៩ ករណីទី១មក

***Date: 19/March/2020***




យើងខ្ញុំសូមជំរាបជូន ដល់សាធារណៈជនមេត្តាជ្រាបថា រាល់ការហៅចូលមកកាន់លេខ ទាន់ហេតុការណ៍ ១១៥ មានពេលខ្លះរង់ចាំយូរ រឺមិនអាចភ្ជាប់បាន

ដោយសារប្រពន្ធ័បានភ្ជាប់ទូរសព្ទ័ដៃ មន្ត្រីចំនួន ២៥នាក់ (២៥ខ្សែរ)រួចហើយ ដែលអ្នកផ្សេងត្រូវរង់ចាំការហៅចូល ហេតុដូច្នេះប្រពន្ធ័នឹងធ្វើការបញ្ជូនការហៅរបស់លោកអ្នក បន្តពីលេខមួយទៅលេខមួយទៀតទៅអ្នកទំនេរ ដោយមិនកាត់ផ្តាច់ការហៅចូលទេ ដែលជាហេតុធ្វើអោយមានការរង់ចាំយូរបន្តិច (អាចលើសពី៣-៥នាទី)។ គួរបញ្ជាក់ផងដែរថា កំឡុងពេលនេះមានការហៅចូលលេខ ១១៥ យ៉ាងច្រើនលើសលុបមិនថាយប់ រឺថ្ងៃ ។ យើងខ្ញុំសូមឲ្យមានយោគយល់និងអត់ធ្មត់ ពីសាធារណ:ជនទាំងអស់ និងសំណូមពរ អោយធ្វើការហៅមកជាថ្មីម្តងទៀត ប្រសិនបើមិនអាចទំនាក់ទំនងបាន។ ក្រុមការងារទូរសព្ទ័ទាន់ហេតុការណ៍លេខ ១១៥ រង់ចាំទទួលនូវការរាយការណ៍ និងសាកសួរពត៌មានអំពីជំងឺ COVID-19 ដោយក្តីសោមនស្សរីករាយ។
សូមជូនទិន្នន័យ ១១៥:
- ក្នុងមួយថ្ងៃហៅចូល និងភ្ជាប់ទំនាក់ទំនងជាង ៩ពាន់នាក់
- សរុបចាប់ពីរកឃើញកូវិត១៩ករណីទី១មក មានជាង៩៣ម៉ឺននាក់
សូមពិនិត្យទិន្នន័យក្រាហ្វិកខាងក្រោមនេះ



## A passenger on flight PG933 from Bangkok to Phnom Penh (9 MARCH 2020) has tested positive for COVID19

***Date: 16/March/2020***




**Old case number 9**: If you were on the same flight PG933 and seated in **rows 22, 23, 24, 25, or 26** you are asked to contact the Ministry of Health of Cambodia by calling 115 (you will hear Khmer language, please press 3). For other passengers on same flight, you are asked to monitor your health for 14 days from the day the flight landed in Cambodia and contact the Ministry of Health by calling 115 if you develop any symptom (fever, cough, shortness of breath or runny nose).

ករណីចាស់ទី៩: អ្នកដំណើរម្នាក់នៅថ្ងៃទី 09-03-2020 លើជើងហោះហើរលេខ PG933 មកពី បាំងកក(BANGKOK) បានធ្វើតេស្តវិជ្ជមានជំងឺកូវីដ-១៩ ។ ប្រសិនបើអ្នកនៅលើជើងហោះហើរតែមួយខាងលើ ហើយអង្គុយនៅជួរទី 22, 23, 24, 25, ឬ 26 អ្នកត្រូវទាក់ទងទៅក្រសួងសុខាភិបាលដោយទូរសព្ទទៅលេខ ១១៥ ។
សម្រាប់អ្នកដំណើរផ្សេងទៀត ដែលធ្វើដំណើរតាមជើងហោះហើរលេខ PG933 អ្នកត្រូវត្រួតពិនិត្យតាមដាន សុខភាពរបស់អ្នករយៈពេល ១៤ ថ្ងៃចាប់ពីថ្ងៃដែលជើងហោះហើរចុះចត នៅប្រទេសកម្ពុជា ហើយទាក់ទងក្រសួងសុខាភិបាលដោយទូរសព្ទទៅលេខ ១១៥ ប្រសិនបើអ្នកមានរោគសញ្ញាណាមួយ។

## របៀបដោះស្រាយ នៅពេលយើងមានបញ្ហាផ្លូវចិត្ត តានតឹង ក្នុងកំឡុងពេលមានការរកឃើញករណីជំងឺកូវិត១៩ ជាបន្តបន្ទាប់ ក្នុងប្រទេសយើង

Date: 15 March 2020



ត័ត៌មានបន្ថែមសូមទាក់ទងលេខ ១១៥

- ក្រសួងសុខាភិបាលកម្ពុជា ដាក់បំរាមផ្អាកមិនអោយជនបរទេស ដែលមកពីប្រទេស អ៊ីតាលី អាល្លឺម៉ង់ អេស្ប៉ាញ បារាំង និង អាមេរិក ចូលមកក្នុងប្រទេសកម្ពុជា
- សូមអរគុណចំពោះ ការខឹតខំប្រឹងប្រែងរបស់មន្ត្រីយើង ក្នុងការទប់ស្កាត់ជំងឺកូវិត១៩ ដោយមិនមានការត្អូញត្អែរពីការនឿយហត់
- សូមអរគុណយ៉ាងជ្រាលជ្រៅ ដល់ក្រសួងទូរគមនាគមន៍កម្ពុជា ដែលបានជួយជួសជុលប្រព័ន្ធ ១១៥ អោយដំណើរការឡើងវិញ
- និយមន័យករណីសង្ស័យ ជំងឺកូវីត-១៩

## Latest Articles

- បច្ចុប្បន្នភាពនៃជំងឺកូរូណាថ្មី COVID-19 នៅប្រទេសកម្ពុជា
- មេរោគកូរ៉ូណាវីរុសប្រភេទថ្មី ឆ្លងតាមរយៈដំណក់ទឹកតូចៗ ដែលខ្ទាតចេញមកក្រៅ តាមរយៈការក្អកឬកណ្តាស់
- លេខ ១១៥ មានអ្នកទូរស័ព្ទចូលរហូតដល់ ជាង៩៣ម៉ឺននាក់ គិតចាប់ពីពេលរកឃើញកូវិត១៩ ករណីទី១មក
- A passenger on flight PG933 from Bangkok to Phnom Penh (9 MARCH 2020) has tested positive for COVID19
- របៀបដោះស្រាយ នៅពេលយើងមានបញ្ហាធុញថប់ តានតឹង ក្នុងកំឡុងពេលមានការរកឃើញ ករណីជំងឺកូវិត១៩ ជាបន្តបន្ទាប់ ក្នុងប្រទេសយើង

## Login Form

User Name

Password

☐ Remember Me

Log in

Forgot your username?
Forgot your password?

## Visitors Counter

| | |
|---|---|
| Today | 512 |
| Yesterday | 2232 |
| This week | 17077 |
| This month | 34591 |
| Total | 966984 |

Powered by CoalaWeb

© 2020 CDC Department Website

Back to Top